00154443

**Declassified to Public**
**06 September 2012**

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

សំណុំរឿងលេខ ៖ ០០២ / ១៤-០៨-២០០៦

ឈ្មោះសំណុំរឿង: **កាំង ហ្គេកអ៊ាវ**

ដាក់ជូន៖ អង្គបុរេជំនុំជម្រះ

កាលបរិច្ឆេទដាក់ជូន៖ ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៧

ដាក់ជូនដោយ: មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម និងគំនិតផ្តួចផ្តើម សំរាប់ភាពយុត្តិធម៌ នៅក្នុងអាស៊ី

ភាសា: អង់គ្លេស

សារណាជូនយោបល់របស់អ្នកមិនមែនជាភាគីក្នុងរឿងក្តីស្តីអំពីការប្តឹងឧទ្ធរណ៍លើដីកាឃុំខ្លួនបណ្តោះអាសន្នកាលពីថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៧ ។

00154444

## មាតិកា

**ការសង្ខេបជាបឋម**

**សេចក្តីផ្តើម**

**យោបល់**

I-ការឃុំខ្លួនពីមុនមកបានរំលោភសិទ្ធិរបស់ភាគីប្តឹងឧទ្ធរណ៍ ហើយអ.វ.ត.កត្រូវតែទទួលស្គាល់ការឃុំខ្លួននោះ ។

II-ការពិនិត្យមើលឡើងវិញលើបណ្តារឿងក្តីនិងភស្តុតាងសំខាន់ៗ បង្ហាញថាការឃុំខ្លួនភាគីបណ្តឹងឧទ្ធរណ៍ពីមុនមកនោះមិនបានបញ្ឈប់ឬហាមឃាត់មិនឱ្យការិយាល័យសហចៅក្រមស៊ើបអង្កេតចេញដីការឃុំខ្លួនឡើយ

ក-ការិយាល័យសហចៅក្រមស៊ើបអង្កេត មានសិទ្ធិចេញដីកាឃុំខ្លួនបណ្តោះអាសន្ន ព្រោះអ.វ.ត.កមិនមានការពាក់ព័ន្ធនឹងការឃុំខ្លួននៅតុលាការយោធាក្រុងភ្នំពេញ។

ខ-ការិយាល័យសហចៅក្រមស៊ើបអង្កេត គួរបដិសេធមិនប្រើអំណាចក្នុងការចេញដីកាឃុំខ្លួនបណ្តោះអសន្នតែក្នុងករណីដែលការឃុំខ្លួនពីមុនមកមានការទាក់ទងទៅនឹងការធ្វើទារុណកម្មឬការធ្វើបាបយ៉ាងធ្ងន់ធ្ងរ ។

គ-ការឃុំខ្លួនពីមុនមកដោយតុលាការយោធាក្រុងភ្នំពេញគួរយកមកពិចារណាក្នុងពេលសម្រេចទោស ។

III-ការពិនិត្យមើលឡើងវិញលើបណ្តារឿងក្តីល្បីៗបង្ហាញឱ្យឃើញថាបទដ្ឋានសម្រាប់ពិនិត្យឡើងវិញរបស់តុលាការដែលចាំបាច់ដើម្បីបដិសេធចោលដីកាឃុំខ្លួនរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតនិងដាក់

ជនជាប់ចោទឱ្យស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការមិនងាយនឹងអាចបំពេញបានទេ។

ក-សេចក្តីសម្រេចឃុំខ្លួនបណ្តោះអាសន្ន គឺជាឆន្ទានុសិទ្ធិរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតតែមួយគត់ ហើយក្នុងករណីចាំបាច់ការិយាល័យសហចៅក្រមស៊ើបអង្កេតអាចធ្វើការពិនិត្យមើលសេចក្តី សម្រេចនោះឡើងវិញ ។

ខ-ការខកខានមិនបានបង្ហាញអង្គហេតុណាមួយក្នុងសំអាងហេតុរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតក្នុងការចេញដីការឃុំខ្លួនបណ្តោះអាសន្នគឺជាកំហុសឆ្គងដែលមិនអាចធ្វើឧទ្ធរណ៍បាន។

គ.ភាគីប្តឹងឧទ្ធរណ៍មានបន្ទុកបង្ហាញសំអាងហេតុថាតើហេតុអ្វីចៅក្រមស៊ើបអង្កេតគួរចេញដីកាដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការ ជាជាដីកាឃុំខ្លួន។

ឃ. សាវនាការលើភាគីប្តឹងឧទ្ធរណ៍នឹងមកដល់ក្នុងពេលដ៏ខ្លី

**<u>សេចក្តីសន្និដ្ឋានៈ</u>**

00154446

**ការសង្ខេបជាបឋម**

១. យើងខ្ញុំសំដៅទៅលើសេចក្តីប្រកាស ជូនដំណឹងជាសាធារណៈ ដែលធ្វើឡើងដោយការិយាល័យ នៃអង្គបុរេជំនុំ ជម្រះចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០៧ បានអញ្ជើញអ្នកមិនមែនជាភាគីដែលមកពីអង្គការ និងសមាជិកសាធារណៈ ឱ្យជូនយោបល់ដល់តុលាការពាក់ព័ន្ធទៅនឹងបណ្តឹងឧទ្ធរណ៍របស់លោក កាំង ហ្កេកអ៊ាវ ហៅ ឌុច ទៅនឹងសេចក្តីសម្រេចឃុំខ្លួនរូបលោកជាបណ្តោះអាសន្ន ដោយការិយាល័យសហចៅក្រមស៊ើប អង្កេត កាលពីថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៧ ។

២. ការដាក់ជូនជាលាយលក្ខអក្សរនេះចាត់ទុកជាសារណារបស់ភាគីមិនមែនជាភាគីនៃរឿងក្តីរួមរវាង៖

ក-មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គមដែលជាអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងស្រុកមួយដែលពុះពារក្នុងកិច្ចការ អង្កេតអំពីសិទ្ធិមនុស្ស យុត្តិធម៌និងការផ្សះផ្សារបង្រួបបង្រួមជាតិនៅកម្ពុជា ។

ខ-គម្រោងគំនិតផ្តួចផ្តើមយុត្តិធម៌អន្តរជាតិនៅក្នុងអាស៊ី ដែលជាគំរោងសហប្រតិបត្តិការមួយរវាង មជ្ឈមណ្ឌលសិក្សាអំពីឧក្រិដ្ឋកម្មសង្គ្រាម នៃសកលវិទ្យាល័យកាលីហ្វ័រញ៉ា **ប៊ើរឃើលី** និងមជ្ឈមណ្ឌល អ៊ីសវ៉េល សេធធឺរ របស់សកលវិទ្យាល័យហាវ៉ៃ ដែលបង្កើតឡើងក្នុងគោលបំណងជំរុញឱ្យមានគំនិតផ្តួចផ្តើមយុត្តិធម៌ និងកម្មវិធីកសាងសមត្ថភាពផ្សេងៗទូទាំងតំបន់អាស៊ីប៉ាស៊ីហ្វិច ។

៣. ថ្វីបើសេចក្តីប្រកាសជូនដំណឹងជាសាធារណៈ បានកំណត់កាលបរិច្ឆេទដាក់សារណាជូនយោបល់របស់អ្នកមិនមែនជាភាគីត្រឹមថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៧ ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលទាក់ទងនឹង បណ្តឹងឧទ្ធរណ៍កាលពីថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០៧ក៏ដោយ ប៉ុន្តែសេចក្តីជូនដំណឹងនេះបានផ្សព្វផ្សាយជាសាធារណៈកាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៧ ពោលគឺយើងមានពេលវេលាចំនួនតែ៤ថ្ងៃគត់ ដើម្បីធ្វើការឆ្លើយតបទៅនឹងបញ្ហា នេះ។ យើងខ្ញុំសូមស្នើថា សូមផ្តល់ឱកាសឱ្យសាធារណៈជន និង អង្គការនានាឱ្យបានគ្រប់គ្រាន់ដើម្បីរៀបចំជា សារណាជូនយោបល់តុលាការនេះ ហើយយើងខ្ញុំសូមរក្សាសិទ្ធិកែប្រែ និង/ឬ បំពេញបន្ថែមនូវចំនុចណាមួយនៃ សារណានេះក្នុងករណីចាំបាច់។

00154447

៤. យើងខ្ញុំសូមគូសបញ្ជាក់ថា សារណាដែលជាសារណាជូនយោបល់របស់អ្នកមិនមែនជាភាគីនេះផ្ទុះបញ្ចាំងពីទស្សនៈអព្យាក្រិត និងឯករាជ្យលើអង្គច្បាប់ដែលបានលើកឡើងក្នុងដីកាឃុំខ្លួនបណ្តោះអាសន្ន ក៏ដូចជាសារណារបស់ភាគីប្តឹងឧទ្ធរណ៍។ ដើម្បីជៀសវាងមន្ទិលសង្ស័យ វិសាលភាពនៃសារណា ជូនយោបល់នេះមានព្រំដែនកំណត់ត្រឹមតែក្នុងការជួយជាគំនិតឱ្យអង្គបុរេជំនុំជម្រះធ្វើការសម្រេចទៅលើអង្គច្បាប់ទាំងឡាយតែប៉ុណ្ណោះ ហើយសារណានេះមិនធ្វើឱ្យប៉ះពាល់ដល់ភាពមានទោសឬគ្មានទោសរបស់ភាគីប្តឹងឧទ្ធរណ៍ក្នុងបទឧក្រិដ្ឋណាមួយដែលខ្លួនកំពុងរងការចោទប្រកាន់នៅមុខអ.វ.ត.កនោះឡើយ។ យើងខ្ញុំកំណត់ព្រំដែនដោយពិនិត្យមើលឡើងវិញតែទៅលើបញ្ហាដែលជាប់ទាក់ទងទៅនឹងច្បាប់អន្តរជាតិ ប៉ុន្តែយើងខ្ញុំមិនជូនយោបល់ពីនីតិវិធី និងអង្គច្បាប់ពាក់ព័ន្ធនឹងការឃុំខ្លួនបណ្តោះអសន្នដែលមានចែងក្នុងច្បាប់កម្ពុជានោះទេ។ការពិនិត្យមើលឡើងវិញរបស់យើងខ្ញុំផ្អែកលើយុត្តិសាស្ត្រ និងការអនុវត្តតាមបណ្តាតុលាការអន្តរជាតិ[1] ក៏ដូចជាតុលាការព្រហ្មទណ្ឌធំៗរុះព្រមទាំងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ។

៥. យើងខ្ញុំដឹងថាក្រៅពីអនុវត្តច្បាប់កម្ពុជា ច្បាប់ស្តីពីការបង្កើតអ.វ.ត.កប្រកាសឱ្យប្រើថ្ងៃទី២៧ ខែតុលាឆ្នាំ២០០៤ និងវិធានផ្ទៃក្នុងរបស់អ.វ.ត.ក អនុម័តថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៧នៅកម្ពុជា (វិធានផ្ទៃក្នុង) អ.វ.ត.ក ត្រូវអនុវត្តសមត្ថកិច្ចរបស់ខ្លួនដោយអនុលោមទៅតាមបទដ្ឋានតុលាការអន្តរជាតិ ភាពយុត្តិធម៌ និងត្រូវ តាមនីតិវិធីច្បាប់ដូចមានចែងក្នុងមាត្រាទី១៤ និង១៥នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិ នយោបាយ ក្រោមមានត្រាទី១២នៃកិច្ចព្រមព្រៀង។

[1] Namely, the International Criminal Tribunal for the Former Yugoslavia ("ICTY") and the International Criminal Tribunal for Rwanda ("ICTR"").

## សេចក្ដីផ្ដើម

៦. អ.វ.ត.ក ទទួលស្គាល់តែបទឧក្រិដ្ឋណាមដែលសាហាវយង់ឃ្នង និងគួរអោយស្អប់ខ្ពើម ដែលប្រព្រឹត្ត ចំពោះ មនុស្សជាតិមានដូចជា អំពើប្រល័យពូជសាសន៍ ឧក្រិដកម្មប្រឆាំងមនុស្សជាតិ និង ឧក្រិដកម្មសង្គ្រាម ដែលធ្ងន់ធ្ងរ ។ ក្នុងដំណាក់កាលវិវត្តន៍ដំបូងៗ អ.វ.ត.កក៏មិនខុសពីបណ្ដាតុលាការឧក្រិដ្ឋកម្មពិសេស និង តុលាការអន្តរជាតិដែលមានយុត្តាធិការកាត់ក្ដីជនជាប់ចោទអំពីបទឧក្រិដ្ឋខាងលើ ត្រូវតែដោះស្រាយនិងថ្លឹងថ្លែង អំពីតម្លៃតបស្នងថាតើ ត្រូវចេញដីកាឃុំខ្លួនបណ្ដោះអសន្ន ឬត្រូវដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យរបស់ តុលាការ។

៧. អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការឧក្រិដ្ឋកម្មចំរុះមួយទៀត (តុលាការពិសេសសំរាប់ Sierra Leone) បានសង្ខេបសេចក្ដីនៃកត្តាត្រូវពិចារណាទាំងឡាយនៅក្នុងករណីរបស់Fofana ដូចតទៅ ៖

“ដោយសារតែមានការប្រឈមជាក់ស្ដែងក្នុងប្រព័ន្ធតុលាការអន្តរជាតិនាពេលបច្ចុប្បន្ននេះ តុលាការត្រូវបង្ហាញ ឱ្យឃើញនូវដំណោះស្រាយមួយដើម្បីធានាថាជនសង្ស័យទាំងនោះត្រូវនាំមកកាន់សាវនាការ និងមិនត្រូវដោះ លែងឱ្យនៅក្រៅឃុំក្នុងស្ថានភាពណាមួយដែលជននោះអាចរត់គេចខ្លួន ឬធ្វើការគំរាមគំហែងដល់សាក្សីខាង អាយ្យការ ឬពួកគេ អាចបន្តសកម្មភាពនានាក្នុងករណីដែលកំពុងចោទប្រកាន់។ប្រការនេះអាចជាការចំអកដល់ ជនរងគ្រោះ ដែលទទួលរងនូវអំពើឧក្រិដ្ឋដ៏សាវយង់ឃ្នង។

ច្បាប់សិទ្ធិមនុស្សដែលផ្ដល់មូលដ្ឋានមួយចំនួនក្នុងការបង្កើតនីតិព្រហ្មទណ្ឌអន្តរជាតិផ្ដល់នូវកំលាំង ដ៏ពិសេសមួយដែលថា ជនណាម្នាក់ដែលត្រូវបានដកហូតសេរីភាពគួរតែមានសិទ្ធិតវ៉ាពីនីត្យានុកូលភាពនៃការឃុំ ឃាំងនោះហើយ លើសពីនេះទៅទៀត ប្រសិនបើការឃុំខ្លួននោះធ្វើឡើងដោយស្របច្បាប់ ជននោះអាចសុំ ការដោះលែងឱ្យមានសេរីភាពបណ្ដោះអាសន្នរង់ចាំសេចក្ដីសម្រេចចុងក្រោយពីតុលាការ។ តាមច្បាប់សិទ្ធិ មនុស្សអន្តរជាតិ សិទ្ធិនេះមិនមែនជាសិទ្ធិ ទទួលបានការដោះលែងទេ ក្នុងន័យថាជននោះមានសិទ្ធិទទួលបាន ការដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន ប្រសិនបើស្ថាប័នធ្វើការចោទប្រកាន់មិនអាចបង្ហាញពីការចោទ ប្រកាន់ជាក់លាក់ណាមួយទៅលើជននោះ។ មានន័យថា វាជាសិទ្ធិដែលអាចសុំទៅតុលាការឱ្យដោះលែងនៅ ក្រៅឃុំដោយសារមានមូលហេតុដែលអាចជឿជាក់បានថាការឃុំខ្លួនចុងចោទមុនពេលជំនុំជម្រះមិនមានភាពចាំ បាច់ក្នុងការធានាប្រសិទ្ធិភាពនៃសាវនាការ ឬដើម្បីហេតុផលសាធារណៈណាមួយឡើយ។”[2]

៨. ការពិចារណាទៅលើចំនុចទាំងនេះ ជាមូលដ្ឋានក្នុងការសម្រេចរបស់ការិយាល័យសហចៅក្រមស៊ើប អង្កេត (ការិយាល័យសហចៅក្រមស៊ើបអង្កេត) ក្នុងការចេញដីការឃុំខ្លួនជាបណ្ដោះអាសន្ន ដីការដោះលែងជា បណ្ដោះអាសន្ន និងដីកាដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការដែលមានចែងក្នុងមាត្រា៦៣-៦៥នៃ

[2] *The Prosecutor v. Fofana*, SCSL-04-14-AR65, Appeal against Decision refusing bail, 11 March 2005, paras 31-32.

វិធានផ្ទៃក្នុង។ ទោះបីវិធានផ្ទៃក្នុងមិនបានបញ្ចូលសេរីភាពជាវិធាន ហើយការឃុំខ្លួនជាអញ្ញាត្រកម្មសម្រាប់ជនជាប់ចោទ កំពុងរង់ចាំការកាត់ក្ដីក៏ដោយ ក៏មិនចាំបាច់ទាមទារឱ្យជនជាប់ចោទបង្ហាញពីកាលៈទេសៈពិសេសដែលកើតមានឡើងមុនពេល ជននោះត្រូវបានដោះលែងឱ្យនៅក្រៅឃុំដែលខុសពីនីតិវិធីនៅICTR។[3] ចៅក្រមស៊ើបអង្កេត អាចចេញដីកាឃុំខ្លួនបណ្ដោះអាសន្ន តែក្នុងករណីដែលខ្លួនយល់ឃើញថា ការឃុំខ្លួនជាវិធានការចាំបាច់។ បើទោះបីជនត្រូវចោទស្ថិតក្នុងការឃុំខ្លួនក៏ដោយចៅក្រមស៊ើបអង្កេតអាចចេញដីកាដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការគ្រប់ពេល ប្រសិនបើចៅក្រមស៊ើបអង្កេតយល់ឃើញថាសមស្រប។ និយាយឱ្យងាយទៅ “ការផ្ដោតជាសំខាន់គឺទៅលើកាលៈទេសៈដោយឡែកក្នុងសំណុំរឿងនីមួយៗ ដោយមិនគិតថា លទ្ធផលចុងក្រោយនោះជាវិធាន ឬជាអញ្ញាត្រកម្មក៏ដោយ”។[4]

៩. ជាវិធានទូទៅមួយ “សេចក្ដីសម្រេចដោះលែងជនជាប់ចោទ គួរផ្អែកលើការវាយតម្លៃទៅលើថាតើផលប្រយោជន៍សាធារណៈដែលអយ្យការបង្ហាញនោះមានទម្ងន់ធ្ងន់ជាងតម្រូវការធានាការគោរពសិទ្ធិទទួលបានសេរីភាពរបស់ជនជាប់ចោទឬទេ។”[5] ម្យ៉ាងវិញទៀត នៅពេលសម្រេចថាតើត្រូវចេញដីកាឃុំខ្លួនបណ្ដោះអាសន្ន ដីកាដោះលែង ឬដីកាដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការឬយ៉ាងណានោះ គឺជាការអនុវត្តអំណាចឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត ប៉ុន្តែក៏ត្រូវថ្លឹងថ្លែងរវាងផលប្រយោជន៍សាធារណៈ និងសិទ្ធិដែលត្រូវទទួលបាន សេរីភាពរបស់ជនត្រូវចោទផងដែរ។

១០. ខណៈពេលដែលសេចក្ដីសម្រេចទាំងនេះគឺជាការជាសម្រេចដោយអំណាចឆន្ទានុសិទ្ធិ ដូចនេះសេចក្ដីសម្រេចទាំងនេះគួរតែត្រូវបានបដិសេធន៍ដោយអង្គបុរេជំនុំជម្រះតាមរយៈបណ្ដឹងឧទ្ធរណ៍ ប្រសិនបើសេចក្ដីសម្រេចទាំងនេះ ត្រូវបានធ្វើឡើងដោយមានកំហុសលើការបកស្រាយនៃច្បាប់ ដោយផ្អែកលើការសន្និដ្ឋានលើអង្គហេតុខុស ឬមិនយុត្តិធម៌ ឬដោយគ្មានហេតុផល អាចនាំឱ្យមានការរំលោភបំពានមួយរបស់សហចៅក្រមស៊ើបអង្កេតក្នុងការអនុវត្តអំណាចឆន្ទានុសិទ្ធិ។[6]

១១. គោលការណ៍ណែនាំដែលយើងបានបង្កើតឡើងខាងលើនេះ ត្រូវអនុវត្តជាមួយគោលការណ៍តុល្យភាពនៃកំលាំងចំពោះរឿងក្ដីនេះ។

---

[3] Rule 65(B) of the ICTR Rules of Procedure and Evidence states that “provisional release may be ordered by a Trial Chamber only in exceptional circumstances, after hearing the host country and only if it is satisfied that the accused will appear for trial and, if released, will not pose a danger to any victim, witness or other person”.

[4] *The Prosecutor v. Sesay*, SCSL-04-15-PT-069, Decision on Application for Provisional Release, paragraph 39. See also *The Prosecutor v Miodrag Jokic* and *The Prosecutor v Rahim Ademi*, IT-01-42-PT and IT-01-46-PT, Orders on Motions for Provisional Release, Trial Chamber, 20 February 2002.

[5] *The Prosecutor v. Sesay*, SCSL-04-15-PT-069, Decision on Application for Provisional Release, para 39.

[6] See *Slobodan Milosovic v The Prosecutor*, Decision on Interlocutory Appeal of the Trial Chamber's Decision on the Assignment of Defence Counsel, ICTY, Case No. IT –02-54-AR7.3.7, 1 November 2004, para 10.

១២. យើងសូមលើកឡើងនូវបញ្ហាច្បាប់ចំនួន៣ផ្សេងគ្នាមកដោះស្រាយ ហើយដែលយើងសង្ឃឹមថានឹងអាចជួយដល់អង្គជំនុំជម្រះក្នុងការចេញសេចក្តីសម្រេចរបស់ខ្លួន។ ចំណុចទី ១ ដោយពិនិត្យមើលយុត្តិសាស្ត្រពាក់ព័ន្ធនឹងករណីនេះ យើងសូមផ្តល់អនុសាសន៍ចំពោះអំណាចឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតក្នុងការចេញសេចក្តីសម្រេចរបស់ខ្លួន និងថាតើអំណាចឆន្ទានុសិទ្ធិនេះត្រូវបានអនុវត្តត្រឹមត្រូវតាមច្បាប់ឬទេ។ ចំណុចនេះហាក់ដូចជាបង្ហាញឲ្យឃើញយ៉ាងច្បាស់ថា ការសម្រេចចិត្តរបស់សហចៅក្រមស៊ើបអង្កេតក្នុងការឃុំខ្លួនបណ្តោះអាសន្នអ្នកបណ្តឹងឧទ្ធរណ៍ ដើម្បីប្រយោជន៍សាធារណៈជន គឺជាការអនុវត្តអំណាចឆន្ទានុសិទ្ធិ ។ លើសពីនេះទៅទៀតដោយពិនិត្យមើលបទដ្ឋានដ៏តឹងរឹងក្នុងការត្រួតពិនិត្យមើលឡើងវិញដែលត្រូវបានដាក់ឲ្យអនុវត្តនៅតុលាការអន្តរជាតិដទៃទៀត យ៉ាងហោចណាស់ក៏មានសំណួរចោទឡើងថាតើសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត អាចជាប្រធានបទនៃបណ្តឹងឧទ្ធរណ៍ដែរឬអត់ ដោយពិចារណាទៅលើគ្រប់កាលៈទេសនិងការអនុវត្តជាក់ស្តែងនៅក្នុងប្រទេសកម្ពុជា ដូចមានចែងដោយសង្ខេបនៅក្នុងកថាខ័ណ្ឌ២២និង ២៣ នៃដីកាឃុំខ្លួន។

១៣. ចំណុចទី ២ យើងសូមផ្តល់អនុសាសន៍លើសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអំពី យុត្តាធិការចំពោះការឃុំខ្លួនលើកមុនរបស់អ្នកប្តឹងឧទ្ធរណ៍។ បន្ទាប់ពីការពិពណ៌អំពីការឃុំខ្លួនលើកមុនរបស់អ្នកប្តឹងឧទ្ធរណ៍ ដោយគ្មានការជំនុំជម្រះរបស់តុលាការយោធាក្រុងភ្នំពេញ ចាប់តាំងពីថ្ងៃទី១០ ខែ មិថុនា ឆ្នាំ ១៩៩៩ រហូតមកដល់ ពេលដែលគាត់ត្រូវបាននាំយកនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ នៅថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៧ (ការឃុំខ្លួនលើកមុន) គឺជាបញ្ហានៃច្បាប់ស្តីអំពីសិទ្ធិមនុស្ស។ ការិយាល័យសហចៅក្រមស៊ើបអង្កេតបានធ្វើការសន្និដ្ឋានថា ដោយយោងទៅតាមច្បាប់[7]ការិយាល័យខ្លួនគ្មានអំណាចយុត្តាធិការលើនីត្យានុកូលភាពនៃការឃុំខ្លួនពីលើកមុនរបស់ឌុចនោះទេ។ សេចក្តីសន្និដ្ឋាននេះ បានគេចចេញពីបញ្ហានៃការឃុំខ្លួនលើមុនរបស់អ្នកបណ្តឹងឧទ្ធរណ៍ និងកំណត់ពីអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន ដែលនេះជាចំណុចដែលយើងត្រូវពន្យល់។ ចំណុច នេះហាក់ដូចជាមានបញ្ជាក់ច្បាស់ពីយុត្តិសាស្ត្រដែលពាក់ព័ន្ធថា ការិយាល័យសហចៅក្រមស៊ើបអង្កេត និងជា ការពិតអង្គបុរេជំនុំជម្រះ គួរអនុវត្តអំណាចយុត្តាធិការជាជាងគេចចេញពីបញ្ហាដែលត្រូវទទួលស្គាល់ថាការឃុំ

ខ្លួនលើកមុនគឺជាការរំលោភទៅលើសិទ្ធិរបស់អ្នកប្តឹងឧទ្ធរណ៍ដែលត្រូវទទួលការជំនុំជម្រះដោយគ្មានពន្យាពេល ដោយយោងទៅលើមាត្រា១៤(៣)(គ)នៃកតិការសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ (ICCPR)។

១៤. ចំណុចទី៣ ដោយយល់ថាការឃុំខ្លួនលើកមុនគឺជាការរំលោភសិទ្ធិរបស់អ្នកប្តឹងឧទ្ធរណ៍ យើងសួរថាតើអ្វីជាសំណងដ៏សមរម្យមួយនោះ? នៅពេលដែលមានការរំលោភសិទ្ធិគឺតម្រូវឲ្យមានសងជាសំណងខ្លះ អង្គជំនុះជម្រះសាលាឧទ្ធរណ៍របស់ICTY បានលើកឡើងជាញឹកញាប់ថា នៅពេលពិចារណាអំពីសំណងសមស្រប

[7] Detention Order, paras 2 and 20.

ចំពោះការចោទប្រកាន់អំពីការរំលោភសិទ្ធិរបស់ជនជាប់ចោទ "តុល្យភាពគឺ.....ត្រូវតែធានារវាងសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទនិងផលប្រយោជន៍ដ៏មានសារៈសំខាន់របស់សហគមអន្តរជាតិក្នុងការកាត់ទោសជនដែលត្រូវចោទប្រកាន់អំពីការរំលោភធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ"។[8] អ្នកប្តឹងឧទ្ធរណ៍បានទទូចថាការដោះលែងរូបគាត់ជាបន្ទាន់គឺជាឧបាស្រ័យតែមួយគត់ប្រឆាំងនឹងការរំលោភបំពានមួយ។ ជាការសន្និដ្ឋាន អ្នកប្តឹងឧទ្ធរណ៍មិនបានលើកអំពីបញ្ហាថាតើការរំលោភបំពានដែលគាត់បានទទួល គឺជាបន្ទុកផ្ទាល់របស់អ.វ.ត.ក ឬអត់ និងអាចមានសមត្ថកិច្ចរឹតត្បិតចំពោះអំណាចឆន្ទានុសិទ្ធិរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតដែលមានចែងក្នុងច្បាប់ និងនៅក្នុងដំណាក់កាលនេះនៃកិច្ចដំណើរការនីតិវិធី។ ប៉ុន្តែជាជម្រើស គាត់បែរជាទាមទារសំណងក្នុងបរិបទនៃការផ្តន្ទាទោស (ប្រសិនបើមានទោស) ឬសំណងជាប្រាក់កាស (ប្រសិនបើលើកលែងចោទប្រកាន់) មិនមែនដោះលែងនោះទេ ដូចមាននៅក្នុងកថាខ័ណ្ឌ១២៧ រហូតដល់ ១៣៣ នៃសារណាប្តឹងឧទ្ធរណ៍របស់គាត់។ ផ្អែកលើការអង្កេតរបស់យើងលើច្បាប់ករណីឬយុត្តិសាស្ត្រ និងការយល់ដឹងរបស់យើងលើខ្លឹមសារវិធានផ្ទៃក្នុង យើងសូមសំណូមពរថា ជម្រើសចំពោះបញ្ហានេះ គឺអាចអាស្រ័យទៅលើយុត្តិសាស្ត្រអន្តរជាតិស្តីពីបញ្ហានេះ ។

១៥. ជាសង្ខេប មានបញ្ហាបីលើកឡើងសំរាប់ការពិចារណារបស់អង្គជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍គឺ៖

ក) ថាតើការឃុំខ្លួនពីមុនមកដោយតុលាការយោធា គឺជារំលោភទៅលើសិទ្ធិរបស់ភាគីប្តឹងឧទ្ធរណ៍ដែរឬអត់ និងប្រសិនបើជាមានការរំលោភសិទ្ធិមែន គួរតែត្រូវបានប្រកាសអំពីករណីរំលោភនេះដោយអង្គបុរេជំនុំជម្រះ។

ខ) ថាតើការរំលោភនោះបានធ្វើឱ្យប៉ះពាល់ ឬដាក់កម្រិតដល់យុត្តាធិការរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតក្នុងការចេញដីកាឃុំខ្លួនដែរឬអត់? និង

គ) ប្រសិនបើការិយាល័យសហចៅក្រមស៊ើបអង្កេតមានសិទ្ធិអនុវត្តអំណាចឆន្ទានុសិទ្ធិរបស់ខ្លួនចំពោះបញ្ហានេះ តើការអនុវត្តនោះគួរត្រូវពិនិត្យឡើងវិញឬទេ។

---

[8] [8] Prosecutor v Nikolic, IT-94-2-AR73, Decision on Interlocutory Appeal Concerning Legality of Arrest, 5 June 2003, para. 30. Prosecutor v Brdjanin, IT-99-36-T, Decision on the Defence Objection to Intercept Evidence, 3 October 2003, para. 61 apply the same principles to other alleged violations of rights.

**មតិយោបល់:**

I. ការឃុំខ្លួនភាគីបណ្តឹងឧទ្ធរណ៍ពីមុនមកដោយតុលាការយោធា បានរំលោភសិទ្ធិរបស់គាត់ ហើយអ.វ.ត.កត្រូវតែទទួលស្គាល់បញ្ហានេះ

១៦. ភាពខុសគ្នាសំខាន់មួយគឺញែកចេញពីគ្នារវាងយុត្តាធិការការិយាល័យសហចៅក្រមស៊ើបអង្កេត ក្នុងការ *ពិនិត្យ សម្រេច និងប្រកាស* អំពីនីត្យានុកូលភាពនៃការឃុំខ្លួនភាគីបណ្តឹងឧទ្ធរណ៍ពីលើកមក ដោយតុលាការយោធា និងយុត្តាធិការការិយាល័យសហចៅក្រមស៊ើបអង្កេតក្នុងការចេញដីកាឃុំខ្លួន ភាគីបណ្តឹងឧទ្ធរណ៍បណ្តោះអាសន្ន ឬឃុំខ្លួនបណ្តោះអាសន្នដោយមានការធានា។

១៧. ការរំលោភទៅលើទ្រឹស្តីនៃដំណើរការនីតិវិធី(ដែលយើងនឹងពិចារណាខាងក្រោម) និងសំណួរ ពាក់ព័ន្ធទៅនឹងថាតើការរំលោភទៅដំណើរការនីតិវិធីលើការឃុំខ្លួនអ្នកប្តឹងឧទ្ធរណ៍ពីលើកមុនគឺជាបន្ទុក របស់អ.វ.ត.កដែរឬទេ។ បញ្ហានេះ គឺពាក់ព័ន្ធទៅនឹងការអនុវត្តអំណាចឆន្ទានុសិទ្ធិរបស់ការិយាល័យ សហចៅក្រមស៊ើបអង្កេត មិនមែនជាការអនុវត្តអំណាចឆន្ទានុសិទ្ធិរបស់តុលាការយោធានោះទេ។

១៨. ការិយាល័យសហចៅក្រមស៊ើបអង្កេត ទំនងជាដាក់បញ្ចូលគ្នានូវទម្រង់យុត្តាធិការពីរដាច់ដោយ ឡែកពីគ្នានៅកថាខណ្ឌ២០នៃដីកាឃុំខ្លួន (បានដាក់ចេញនិងពិភាក្សាខាងក្រោម)។ ការិយាល័យសហ ចៅក្រមស៊ើបអង្កេតគួរតែសួរអំពីបញ្ហាពីមុនមក(ថាតើយើងអាចសម្រេចលើបញ្ហានីត្យានុកូលភាព ចំពោះការឃុំខ្លួនពីលើកមុនរបស់អ្នកប្តឹងឧទ្ធរណ៍ដែរឬអត់ ទោះបីជាអ.វ.ត.កទើបតែចាប់ផ្តើមដំណើរ ការនៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៦ និងមិនទទួលខុសត្រូវដោយផ្ទាល់ចំពោះការឃុំខ្លួនលើកមុននោះ ទេ?)

១៩. អង្គជំនុំជម្រះឧទ្ធរណ៍របស់ICTR បានឆ្លើយនូវសំណួរនេះក្នុងលក្ខណៈវិជ្ជមានមួយនៅក្នុងសេចក្តី សម្រេចរបស់ខ្លួនលើរឿងក្តីលោក*Barayagwiza* ដែលអង្គជំនុំជម្រះឧទ្ធរណ៍ជឿថា ការរំលោភដល់ សិទ្ធិរបស់ជនជាប់ចោទក្រោមច្បាប់ ត្រូវតែទទួលស្គាល់ដោយតុលាការឧក្រិដ្ឋកម្មអន្តរជាតិដែលនៅ ចំពោះមុខតុលាការនេះហើយដែលជនជាប់ចោទស្វែងរកជំនួយ ទោះបីជាការរំលោភសិទ្ធិនោះមិនមែន ជាសមត្ថកិច្ចផ្ទាល់របស់តុលាការនោះក៏ដោយ៖

> “ក្នុងសំណុំរឿងក្តីបច្ចុប្បន្ន ភាគីបណ្តឹងឧទ្ធរណ៍ត្រូវបានឃុំខ្លួនអស់រយៈពេលសរុប១១ខែ មុន ពេលគាត់បានទទួលសេចក្តីជូនដំណឹងអំពីប្រភេទនៃការចោទប្រកាន់ដែលព្រះរាជអាជ្ញាបាន ប្តឹងប្រឆាំងនឹងគាត់។ នៅពេលដែលយើងទទួលស្គាល់ថា មានតែរយៈពេល៣៥ថ្ងៃប៉ុណ្ណោះ

00154453

ក្នុងចំណោមរយៈពេលសរុប១១ខែ ដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់តុលាការ (រយៈពេលចាប់ពីថ្ងៃទី១៧ ខែមេសា-១៦ឧសភា ឆ្នាំ១៩៨៦ និងថ្ងៃទី៤-១០ ខែមិនា ឆ្នាំ១៩៨៧) ការពិតនោះគឺថាភាគីបណ្តឹងឧទ្ធរណ៍បានចំណាយពេលវេលាច្រើនហួសហេតុនៅក្នុងការឃុំខ្លួនបណ្តោះអាសន្ន ដោយពុំបានដឹងប្រភេទនៃការចោទប្រកាន់ចំពោះរូបគាត់។

**<u>នៅក្នុងចំណុចបន្តនេះ</u> គឺដូចជាមិនសមហេតុផលទេដែលថា មានតែមួយរយៈពេលមួយខ្លីក្នុងរយៈពេលសរុបនៃការឃុំខ្លួនបណ្តោះអាសន្ន គឺជាបន្ទុកសមត្ថកិច្ចរបស់តុលាការ ដោយហេតុថាស្ថាប័ននេះគឺជាតុលាការ(មិនមានជាអង្គភាពណាមួយផ្សេងទេ)ដែលបច្ចុប្បន្ននេះជាអង្គជំនុំជម្រះលើការតវ៉ារបស់ភាគីប្តឹងឧទ្ធរណ៍។ ដោយមិនគិតថាភាគីណាជាអ្នកទទួលខុសត្រូវទេ ការសន្និដ្ឋានមួយដែលមិនអាចចៀសវាងបាន គឺថាសិទ្ធិរបស់ភាគីបណ្តឹងឧទ្ធរណ៍ក្នុងការទទួលសេចក្តីជូនដំណឹងទាន់ពេលវេលាអំពីការចោទប្រកាន់ចំពោះខ្លួន ត្រូវបានរំលោភបំពាន"។**

(នេះជាសេចក្តីបញ្ជាក់បន្ថែម)

២០. បន្ទាប់មក ការិយាល័យសហចៅក្រមស៊ើបអង្កេតមានយុត្តាធិការដើម្បីសម្រេចនិងប្រកាសថាតើការឃុំខ្លួនពីមុនមករយៈពេលជាង៨ឆ្នាំបានរំលោភសិទ្ធិភាគីប្តឹងឧទ្ធរណ៍ដែរឬទេ។

២១. ច្បាប់ករណីផ្តល់យោបល់ថា មិនមានវិធានល្អដើម្បីកំណត់ថាតើរយៈពេលជាក់លាក់ណាមួយនៃការឃុំខ្លួនបញ្ជាក់ថាការពន្យារមិនត្រឹមត្រូវពេលមុនការជំនុំជម្រះទោស ជាការរំលោភលើវិធាន១៤ (៣) (គ)នៃ ICCPR។ គ្មានសេចក្តីសម្រេចណានៃសេចក្តីសម្រេចរបស់គណៈកម្មាធិការសិទ្ធិមនុស្សឬតុលាការសិទ្ធិមនុស្សអឺរ៉ុប(ECHR)ដែលត្រូវបានដកស្រង់ដោយភាគីប្តឹងឧទ្ធរណ៍ក្នុងកថាខណ្ឌ៣២ ដល់៨១នៃសារណាបណ្តឹងឧទ្ធរណ៍របស់គាត់ អនុម័តយកយន្តការមួយចំពោះការឃុំខ្លួនមុនការកាត់ទោស ឬកំណត់ពេលវេលាតាមចិត្តឬដោយជាក់លាក់ដែលអាចយកមកអនុវត្តបានចំពោះគ្រប់រឿងក្តីដែលមានការពន្យារពេលនោះ ជាជាងការពិចារណាលើអង្គហេតុនិងអង្គសេចក្តីនៃរឿងក្តីនីមួយៗ។ ជាការពិត តុលាការសិទ្ធិមនុស្សអឺរ៉ុបបានចៀសវាងការកំណត់ពេលជាក់លាក់ និងបានដោះស្រាយបណ្តឹងទាក់ទងទៅនឹងការឃុំខ្លួនរង់ចាំការជំនុំជម្រះ ដោយការពិចារណាកត្តានានាជាបន្តបន្ទាប់នៅក្នុងកាលៈទេសៈនៃករណីរឿងក្តីជាក់ស្តែង។ ប្រហាក់ប្រហែលគ្នានេះដែរ ជាការពិតនោះគឺ គណៈកម្មាធិការសិទ្ធិមនុស្សបានរកឃើញរយៈពេលនៃការឃុំខ្លួនមិនសមហេតុផលនៅក្នុងកាលៈទេសៈមួយ មិនមែនមាន

ន័យថា ការឃុំខ្លួនរយៈពេលប្រហាក់ប្រហែលគ្នានេះនៅក្នុងកាលៈទេសៈដទៃទៀត ត្រូវបានពិចារណាថាមិនសមហេតុផលនោះទេ។

២២. ថ្វីបើដូច្នេះក៏ដោយ និងបើទោះណាជាយើងមិនមានផលអំពីបំណកស្រាយស្តីពីការដាក់សេចក្តីសន្និដ្ឋានរបស់អយ្យការ ឬសំណុំរឿងរបស់តុលាការយោធាដែលទាក់ទងទៅនឹងបញ្ហានេះរបស់អ្នកប្តឹងឧទ្ធរណ៍ ក៏យើងមានទំនោរជឿថា ការឃុំខ្លួនភាគីប្តឹងឧទ្ធរណ៍ពីលើកមុនមក គឺជារំលោភសិទ្ធិរបស់គាត់ដែលត្រូវទទួលបានការកាត់សេចក្តីក្នុងរយៈពេលមួយសមស្រប ឬត្រូវដោះលែង យោងតាមច្បាប់អន្តរជាតិ។ យើងយល់ស្របជាមួយនឹងអំណះអំណាងផ្លូវច្បាប់ដែលដកស្រង់ក្នុងកថាខណ្ឌ៣៨-៥៥ នៃបណ្តឹងឧទ្ធរណ៍របស់ភាគីប្តឹងឧទ្ធរណ៍ ដែលគាំទ្រដល់សំណើនេះ(តែសំណើនេះប៉ុណ្ណោះ)។

២៣. ដោយទទួលស្គាល់ថា ការឃុំខ្លួនភាគីប្តឹងឧទ្ធរណ៍ពីលើកមុនមក គឺជាបញ្ហាមួយក្នុងទស្សនៈនៃច្បាប់ជាធរមាន ក្នុងកថាខណ្ឌ២នៃដីកាបង្គាប់ឱ្យឃុំខ្លួន ការិយាល័យសហចៅក្រមស៊ើបអង្កេតត្រូវបន្តទទួលស្គាល់ថា មានការរំលោភសិទ្ធិគាត់ ដោយយោងទៅតាមច្បាប់។ ផ្ទុយទៅវិញ ការិយាល័យសហចៅក្រមស៊ើបអង្កេតចៀងវាងបញ្ហានេះដោយនិយាយថា មិនមានយុត្តាធិការទាល់តែសោះក្នុងការស៊ើបសួរបញ្ហានេះ។ ដូច្នេះយើងសូមជម្រុញឱ្យអង្គបុរេជំនុំជម្រះពិនិត្យមើល សម្រេចនិងប្រកាសអំពីនីត្យានុកូលភាពនៃការឃុំខ្លួនភាគីប្តឹងឧទ្ធរណ៍ពីលើកមុន នៅក្នុងដីកាសម្រេចសេចក្តីរបស់ខ្លួន។

**II. ការពិនិត្យមើលលើរឿងក្តីសំខាន់ៗបង្ហាញថា ការឃុំខ្លួនពីមុនលើភាគីបណ្តឹងឧទ្ធរណ៍ ពុំបានរារាំង ឬទប់ស្កាត់ការិយាល័យសហព្រះរាជអាជ្ញាពីការធ្វើដីកាបង្គាប់ឱ្យឃុំខ្លួនឡើយ។**

**២៤.** ឧបមាថា ការឃុំខ្លួនគាត់ពីមុនគឺជាការរំលោភដល់សិទ្ធិរបស់គាត់ តើវាមានផលប៉ះពាល់អ្វីខ្លះអំពីបញ្ហាដែលថា គាត់គួរត្រូវឃុំខ្លួនជាបណ្តោះអាសន្នរង់ចាំការជំនុំជម្រះក្តីរបស់ អ.វ.ត.ក តទៅទៀត ឬយ៉ាងណា?

**២៥.** ភាគីបណ្តឹងឧទ្ធរណ៍ទទូចថា ផលវិបាក និងដំណោះស្រាយចំពោះការរំលោភនោះគឺការដោះលែងគាត់ឱ្យនៅក្រៅឃុំឱ្យបានឆាប់។

**២៦.** ភាគីបណ្តឹងឧទ្ធរណ៍យកលើរឿងក្តីរបស់ <u>*Barayagwiza*</u> មកធ្វើជាយុត្តិសាស្ត្រក្នុងការអះអាងថា ការរំលោភសិទ្ធិរបស់គាត់ក្រោមការឃុំខ្លួនពីមុនមកនេះ ធ្វើឱ្យប៉ះពាល់ដល់ឆន្ទានុសិទ្ធិនៃការិយាល័យសហចៅក្រមស៊ើបអង្កេតក្នុងការផ្តល់ការអនុញ្ញាត ឬ បដិសេធដល់ការដោះលែងបណ្តោះអាសន្ន។ ប៉ុន្តែ ត្រូវចងចាំថា ក្នុងរឿងក្តីនោះ អង្គជំនុំជម្រះឧទ្ធរណ៍របស់ ICTR បានធ្វើការសម្រេចក្នុងបរិបទ

00154455

សាលក្រម និងការផ្តន្ទាទោស។ ឬអាចនិយាយបានម្យ៉ាងទៀតថា ការលៃលកពេលវេលានៃសេចក្តីសម្រេចចិត្ត ក៏ត្រូវតែយកមកគិតពិចារណា។ កត្តាសំខាន់ដែលត្រូវយកចិត្តដាក់គឺថា អង្គជំនុំជម្រះ បានកម្រិតការសង្កេត និង ការសម្រេចរបស់ខ្លួនទៅលើ "ចំនុចនៃពេលវេលា" ឬ ដំណាក់កាលនៃ ការស៊ើបអង្កេតប៉ុណ្ណោះ (សូមមើលសម្រង់ខាងលើនៅកថាខណ្ឌ១៩)។ យោងតាមសេចក្តីសន្និដ្ឋានោះ ជាការសំខាន់ជាពិសេស ឬ ជាការចាំបាច់មួយ ដែលគេផ្តើតទំនាក់ទំនងគ្នាមួយរវាងការប្រព្រឹត្តិល្មើស ឬការរំលោភបំពានលើនីតិវិធី ដូច្នេះតាមការបកស្រាយរបស់យើងគឺថា អ.វ.ត.ក ក្លាយជាអង្គហេតុ នៃការពិចារណាយ៉ាងប្រាកដប្រជាមួយ នៅពេលគេធ្វើការសម្រេចចិត្តថាតើការិយាល័យសហចៅក្រមស៊ើបអង្កេតត្រូវមានសិទ្ធិចេញដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្នឬយ៉ាងណានោះ។

២៧. ភាគីបណ្តឹងឧទ្ធរណ៍ ពុំបានលើកឡើងអំពីសេចក្តីសម្រេចថ្មីៗ និងដែលសំខាន់មួយក្នុងរឿងក្តី Lubanga ទេ ដែលក្នុងរឿងក្តីហ្នឹង អង្គជំនុំជម្រះឧទ្ធរណ៍របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) បានចាត់ទុកថាជាបញ្ហាដ៏សំខាន់មួយដូចគ្នានឹងបញ្ហាដែលអង្គជំនុំជម្រះប្រកបដោយកិត្តិយសនេះកំពុងប្រឈមមុខក្នុងពេលឥឡូវនេះ ឧទាហរណ៍ថាតើនឹងអាចមានស្ថានភាពនៃអត្ថិភាពនៃការរំលោភបំពានសិទ្ធិមនុស្ស ដែលអាចនាំឲ្យមានការរារាំង ឬ រឹតត្បិតការអនុវត្តន៍នៃយុត្តិសាស្ត្រសាលាក្តីព្រហ្មទណ្ឌអន្តរជាតិដែរឬទេ ក្នុងការចេញដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្នបែបនេះ។

២៨. អង្គហេតុនៃរឿងក្តីរបស់ *លូបាំងហ្គា* គឺមានលក្ខណៈស្រដៀងគ្នាទៅនឹងរឿងក្តីរបស់ភាគីបណ្តឹងឧទ្ធរណ៍ដែរ។ ក្នុងរឿងក្តីនោះ លូបាំងហ្គា ត្រូវបានចាប់ខ្លួន និងឃុំខ្លួនទាក់ទងនឹងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខតុលាការយោធារបស់សាធារណៈរដ្ឋប្រជាមានិតកុងហ្គោ រហូតទាល់តែគាត់ត្រូវបានផ្ទេរទៅកាន់តុលាការ ICC ដែលជាផ្នែកមួយនៃកិច្ចដំណើរការតុលាការផ្ទាល់របស់ខ្លួន និងអនុលោមតាមសំណើសុំសហប្រតិបត្តិការរបស់ ICC ចុះថ្ងៃទី១៤ ខែមិនា ឆ្នាំ២០០៦។ បញ្ហាមួយនៅចំពោះមុខអង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការ ICC គឺថាតើវាជាការរំលោភសិទ្ធិមនុស្សដែលទទួលស្គាល់ជាអន្តរជាតិដែរឬយ៉ាងណាចំពោះករណីរបស់ លូបាំងហ្គា ទាក់ទងនឹងការចាប់ខ្លួននិងការឃុំខ្លួនដោយសាធារណៈរដ្ឋប្រមានិតកុងហ្គោ នៅមុនថ្ងៃ ទី១៤ ខែមិនា ឆ្នាំ២០០៦ ដែលធ្វើឱ្យប៉ះពាល់ដល់យុត្តាធិការ ICC ក្នុងការចេញដីកាឃុំខ្លួនបណ្តោះអាសន្ននេះនោះ។

**២៩.** បន្ទាប់ពីត្រួតពិនិត្យសព្វគ្រប់អំពីនីតិសាស្ត្រ និងការអនុវត្តពាក់ព័ន្ធរបស់តុលាការឧក្រិដ្ឋកម្មកូនកាត់និងតុលាការអន្តរជាតិផ្សេងៗ អង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការ ICC បានដាក់ចេញនូវគោលការណ៍ដូចខាងក្រោមនេះ៖

ក) ការរំលោភបំពានណាមួយទៅលើសិទ្ធិរបស់ជនជាប់ចោទទាក់ទងនឹងការចាប់ខ្លួននិងឃុំខ្លួនពីមុនមក ដែលធ្វើឡើងដោយអាជ្ញាធរពីខាងក្រៅ គឺជាការទទួលខុសត្រូវរបស់តុលាការឧក្រិដ្ឋកម្ម ប្រសិនបើត្រូវបានគេរកឃើញពីដំបូងថា មានចំណាត់ការរួមរវាងតុលាការឧក្រិដ្ឋកម្ម និងអាជ្ញាធរទាក់ទងនឹងការរំលោភទាំងនោះ។

ខ) ទោះបីជាពុំមានចំណាត់ការរួមរវាងតុលាការឧក្រិដ្ឋកម្ម និងអាជ្ញាធរពីខាងក្រៅទាំងនេះក៏ដោយ ការប្រើប្រាស់ខុសនីតិវិធីត្រូវចាត់ទុកថាជាការធានាបន្ថែមដល់សិទ្ធិរបស់ជនជាប់ចោទ។

គ) ទោះបីវាជាការដាក់កម្រិតចំពោះ បណ្តឹងទាំងឡាយ អំពីការធ្វើទារុណកម្មនិងការរំលោភធ្ងន់ធ្ងរពីសំណាក់អាជ្ញាធរពីខាងក្រៅ ឬបណ្តឹងទាំងឡាយទាក់ទងនឹងនីតិវិធីចាប់ខ្លួននិងបញ្ជូនខ្លួនទៅកាន់តុលាការឧក្រិដ្ឋកម្ម ការអនុវត្តទ្រឹស្តីខុសនីតិវិធី (ដែលអាចនឹងតម្រូវឱ្យតុលាការឧក្រិដ្ឋកម្មបដិសេធការអនុវត្តន៍យុត្តាធិការក្នុងរឿងក្តីពិសេសមួយបាន)។

**៣០.** គ្មានភស្តុតាងបង្ហាញថា ការចាប់ខ្លួននិងការឃុំខ្លួន *Lubanga* មុនថ្ងៃទី១៤ ខែមិនា ឆ្នាំ២០០៦ គឺជាលទ្ធផលបង្ហាញពីចំណាត់ការរួមរវាងតុលាការ ICC និងអាជ្ញាធរសាធារណៈរដ្ឋប្រជាមានិត កុងហ្គោ ឬគ្មានភស្តុតាងបង្ហាញថា គាត់ត្រូវបានគេធ្វើទារុណកម្ម ឬរំលោភយ៉ាងធ្ងន់ធ្ងរក្នុងពេលណា មួយឡើយ អង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការ ICC សម្រេចថា ខ្លួនមានសិទ្ធិឃុំខ្លួន *Lubanga* បណ្តោះអាសន្ន និង ចាត់ការបន្តដូច្នេះបាន។

***ក) ការិយាល័យសហចៅក្រមស៊ើបអង្កេត មានសិទ្ធិចេញដីកាឃុំខ្លួនបណ្តោះអាសន្ន ហើយ ទុកចំណាត់ការរួម រវាង អ.វ.ត.ក និងតុលាការយោធាដោយឡែក។***

**៣១.** ភាគីបណ្តឹងឧទ្ធរណ៍ទំនងជាមិនអាចរកឃើញថា មានចំណាត់ការរួមរវាង អ.វ.ត.ក និងតុលាការយោធាទេ។

**៣២.** ភាគីបណ្តឹងឧទ្ធរណ៍៖

១) ចង្អុលបង្ហាញពីសេចក្តីយោងនៅក្នុងដីកាឃុំខ្លួនលើកមុន ដែលធ្វើឡើងដោយតុលាការយោធា ទាក់ទងនឹងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

២) បញ្ជាក់ថា តុលាការយោធាពុំបានពន្យល់អំពីការឃុំខ្លួនភាគីបណ្តឹងឧទ្ធរណ៍នោះឡើយ។

៣) កាត់យល់បានថា អ្វីដែលតុលាការយោធាធ្វើនោះ អាចជាការពន្យាពេលដល់ការឃុំខ្លួនភាគីបណ្តឹងឧទ្ធរណ៍មុនការជំនុំជម្រះ និង

៤) បញ្ជាក់ថា គេអាចទំលាក់កំហុសអំពីការឃុំខ្លួនពីមុននោះ ទៅលើអាជ្ញាធរតុលាការកម្ពុជា (រួមទាំង អ.វ.ត.ក ផងដែរ)

ដើម្បីបញ្ជាក់ថា អ.វ.ត.ក ទទួលខុសត្រូវចំពោះការឃុំខ្លួនពីមុនមក។

៣៣. ទោះយ៉ាងណា ការពិតដែលថា អ.វ.ត.ក គឺជាផ្នែកមួយនៃប្រព័ន្ធតុលាការកម្ពុជា ក៏ការពិតនោះ ពុំគួរចាំបាច់នាំទៅរកការសន្និដ្ឋានមួយដែលថា តុលាការអន្តរជាតិពិសេសនេះ បំពេញការងាររួមគ្នាជា មួយតុលាការយោធា (អាជ្ញាធរតុលាការដោយឡែកមួយ) ដែលមិនទទួលខុសត្រូវចំពោះសំណុំរឿងភាគីបណ្តឹងឧទ្ធរណ៍នៅចំពោះមុខ អ.វ.ត.ក។ យើងមិនជំទាស់ទេថា ការឃុំខ្លួនរបស់តុលាការយោធា បង្ហាញបន្ថែមអំពីការរំលោភយ៉ាងច្បាស់តាំងតែពីលើកដំបូងទៅលើសិទ្ធិរបស់ភាគីបណ្តឹងឧទ្ធរណ៍ ប៉ុន្តែ គេមិនអាចចោទប្រកាន់ច្បាស់លាស់ចំពោះ អ.វ.ត.ក នោះទេ។ ការជំទាស់របស់ភាគីបណ្តឹងឧទ្ធរណ៍ គួរតែធ្វើជាមួយតុលាការយោធា មិនមែនជាមួយ អ.វ.ត.ក នោះឡើយ។ ភាគីបណ្តឹងឧទ្ធរណ៍មានសិទ្ធិ ស្វែងរកសំណងចំពោះការរំលោភនៅចំពោះមុខ អ.វ.ត.ក (ចូរមើលខាងក្រោម) ប៉ុន្តែករណី យុត្តិសាស្ត្រអន្តរជាតិទំនងជាស្នើយោបល់ថា ភាគីបណ្តឹងឧទ្ធរណ៍មិនអាចលើកបញ្ហានេះជាខែលមួយ ប្រឆាំងនឹងការអនុវត្តឆន្ទានុសិទ្ធិនៃ អ.វ.ត.ក ក្នុងការចេញដីកាឃុំខ្លួនបណ្តោះអាសន្ននេះបានឡើយ ។

៣៤. តាមការពិតដែលទទួលបាន វាហាក់ដូចជាមានទំនាក់ទំនងមួយរវាងចរិតនិងវិសាលភាពនៃការចោទប្រកាន់ ដែលភាគីបណ្តឹងឧទ្ធរណ៍បានប្រឈមមុខចំពោះតុលាការយោធា និងការចោទប្រកាន់ទាំងឡាយដែល អ.វ.ត.ក បានធ្វើឡើងចំពោះរូបគាត់។ ប៉ុន្តែនេះមិនបង្ហាញឱ្យឃើញថា ជាចំណាត់ការរួម ឬជាការផ្សំគំនិតនៃប្រភេទណាមួយរវាងអង្គភាពច្បាប់ដាច់ឡែកទាំងនេះទេ ហើយក៏មិនបង្ហាញឱ្យឃើញថា ការចោទប្រកាន់ទាំងនោះត្រូវបានស្នើឡើងដោយភាគីបណ្តឹងឧទ្ធរណ៍យ៉ាងច្បាស់លាស់នោះដែរ។ ប្រសិនបើមានភស្តុតាងបង្ហាញពីការរួមគំនិត ឬចំណាត់ការរួមបែបណាមួយនោះ ការឃុំខ្លួនពីមុនមកនោះ ត្រូវពិនិត្យឱ្យបានម៉ត់ចត់ក្នុងដំណាក់កាលនេះ។ ហេតុដូច្នេះ ចេញពីការអង្កេតលើយុត្តិសាស្ត្រពាក់ព័ន្ធ វាហាក់ដូចជាថា ការដាក់ទោសគឺជាដំណាក់កាលសមស្របបំផុតដើម្បីដោះស្រាយនូវផលប៉ះពាល់នេះ (យើងសូមធ្វើការពិពណ៌នាលំអិតបន្ថែមនៅកថាខណ្ឌ៣៦ និង៣៧)។ ដូចបានកត់សំគាល់ដោយអង្គជំនុំជម្រះសាលាដំបូងរបស់ ICTR លើរឿងក្តី *Kajelijeli* ភាគីចុងចោទគួរមានសិទ្ធិ

00154458

ស្ដីបន្ទោសទៅលើរយៈពេលដែលបានឃុំខ្លួនគាត់ រួមទាំងរយៈពេលដែលគាត់ត្រូវឃុំខ្លួនក្រោមដីកា នាំខ្លួន ដែលជាដីការបស់រដ្ឋ ប្រសិនបើដីកានោះ *"ផ្ដោតលើការចោទប្រកាន់តែមួយដែលបង្កើតបានជាប្រធានបទនៃការជំនុំជម្រះ"*។

***ខ) ការិយាល័យសហចៅក្រមស៊ើបអង្កេត គួរបដិសេធនូវការអនុវត្តអំណាចចេញដីកាឃុំខ្លួនបណ្ដោះអាសន្ន ប្រសិនបើការឃុំខ្លួនពីមុនមកនោះមានការជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្ម និងការរំលោភធ្ងន់ធ្ងរ។***

**៣៥.** ភាគីបណ្ដឹងឧទ្ធរណ៍ពុំបានផ្ដល់ភស្ដុតាង ដែលគាត់បានទទួលរងនូវការឈឺចាប់ពីទម្រង់ណាមួយ នៃការធ្វើទារុណកម្ម ឬការរំលោភធ្ងន់ធ្ងរនៅពេលដែលគាត់ឋិតនៅក្នុងដៃតុលាការយោធា ឬអាជ្ញាធរ អនុវត្តច្បាប់ ក្នុងអំឡុងពេលនៃការឃុំខ្លួនពីមុនមកនោះ។ ការពុំបានបង្ហាញភស្ដុតាងបែបនេះ ករណីនីតិ សាស្ត្រអន្តរជាតិក្នុងរឿងក្ដី *Lubanga* ស្នើយោបល់ថា ក្នុងស្ថានភាពនេះ មិនអាចយកទ្រឹស្ដីនីតិវិធីមក ប្រើប្រាស់ខុសនោះទេ។ ដោយឡែក ទោះបីវាជាការរំលោភទៅលើសិទ្ធិរបស់ភាគីបណ្ដឹងឧទ្ធរណ៍ ក៏ ការឃុំខ្លួនពីមុននោះ មិនអាចបូកបន្ថែមជាមួយនឹងការប្រើប្រាស់ខុសនីតិវិធីរបស់អ .វ.ត.ក ដែលខ្លួន អាចតម្រូវឱ្យការិយាល័យសហចៅក្រមស៊ើបអង្កេត បដិសេធនូវការអនុវត្តយុត្តាធិការរបស់ខ្លួនក្នុង រឿងក្ដីនេះ។ វាហាក់បីដូចជាករណីយុត្តិសាស្ត្រថ្មីៗនេះមានលក្ខណៈអូសទាញ បន្ទាប់ពីការពិចារណា អំពីការពិតដែលចេញមកពីICC ហើយដែលលក្ខន្តិកៈក្រុងរ៉ូមត្រូវបានប្រទេសចំនួន១០៥អនុម័តទូទាំង ពិភពលោក (ក្នុងនោះមានប្រទេសកម្ពុជាមួយដែរ)។

***គ) ការឃុំខ្លួនដោយតុលាការយោធាក្រុងភ្នំពេញ គួរយកមកពិនិត្យដើម្បីដាក់ទោស។***

**៣៦.** យើងមិនមានបំណងស្នើយោបល់ឱ្យភាគីបណ្ដឹងឧទ្ធរណ៍ ត្រូវគេទុកចោលដោយគ្មានបានទទួលសំណងណាមួយចំពោះការឃុំខ្លួនរបស់គាត់ពីមុនមក ដែលវាជាការរំលោភជាក់ស្ដែងបន្ថែមទៀតទៅលើសិទ្ធិរបស់គាត់ ហើយក៏គ្មានបំណងស្នើយោបល់ឱ្យទុកចោលគ្មានការជំនុំជម្រះក្នុងពេលវេលាមួយសមស្រប ឬត្រូវដោះលែងនោះឡើយ។

*Kajelijeli:*

"នៅពេលណាសិទ្ធិរបស់ជនសង្ស័យ ឬសិទ្ធិរបស់ជនជាប់ចោទណាម្នាក់ ត្រូវបានគេរំលោភក្នុងអំឡុងពេលនៃការឃុំខ្លួនគាត់ដោយខុសច្បាប់រង់ចាំការផ្ទេរ និងការជំនុំជម្រះ មាត្រា២ (៣)(ក)នៃ ICCPRចែងថា បុគ្គលណាក៏ដោយដែលមានសិទ្ធិ ឬសេរីភាពដែលគេទទួលស្គាល់

00154459

ហើយត្រូវគេ រំលោភនោះ បុគ្គលនោះត្រូវទទួលបានសំណងដោយប្រសិទ្ធិភាពមួយ ទោះបីការរំលោភនោះបាន ប្រព្រឹត្តឡើងដោយបុគ្គលទាំងឡាយដែលបំពេញការងារផ្លូវការក៏ដោយ”។

៣៧. ទាក់ទងនឹងបញ្ហានេះ យើងសូមជំរុញឱ្យអង្គជំនុំជម្រះ(Honourable Chamber)ពិនិត្យលើការ សម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងICTR លើរឿងក្តីBarayagwisa (ដែលភាគីបណ្តឹងឧទ្ធរណ៍ យកជាសំអាង) និងKajelijeli នៅពេលធ្វើការសម្រេចណាមួយ ទាក់ទងនឹងមូលហេតុបណ្តឹងឧទ្ធរណ៍លើកទីបីនិងចុងក្រោយរបស់ភាគីបណ្តឹងឧទ្ធរណ៍ ប៉ុន្តែក្នុងកម្រិតមួយដែលទាក់ទងនឹងដំណោះស្រាយ ជាជំរើសក្នុងការដាក់ទោស និងសំណងហរិញ្ញវត្ថុ។

**III. ការពិនិត្យឡើងវិញអំពីរឿងក្តីសំខាន់ៗ បង្ហាញថា បទដ្ឋាននៃការត្រួតពិនិត្យរបស់តុលាការ តម្រូវឱ្យលុបចោលដីកាឃុំខ្លួនរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត និងការមិនអាចបំពេញបានដោយងាយនូវការផ្តល់កិច្ចធានាឱ្យនៅក្រៅឃុំ**

***ក) ការិយាល័យសហចៅក្រមស៊ើបអង្កេត មានឆន្ទានុសិទ្ធិក្នុងការចេញដីកាឃុំខ្លួនបណ្តោះអាសន្ន ឬចេញដីកាដោះលែងឱ្យនៅក្រៅឃុំ និងពិនិត្យសារជាថ្មីនូវការសម្រេចរបស់ខ្លួន។***

៣៨. ដូចយើងបានពោលរួចមកហើយ ការសម្រេចណាមួយដោយការិយាល័យសហចៅក្រមស៊ើបអង្កេតក្នុងការចេញដីកាឃុំខ្លួនបណ្តោះអាសន្ន ឬចេញដីកាដោះលែងឱ្យនៅក្រៅឃុំ គឺជាការសម្រេចដោយឆន្ទានុសិទ្ធិសុទ្ធសាធ។ នោះជាសារៈសំខាន់។ អង្គជំនុំជម្រះឧទ្ធរណ៍នៅតុលាការឧក្រិដ្ឋកម្មក្នុងកាត់ និងតុលាការអន្តរជាតិដទៃទៀត បានរកឃើញ បទដ្ឋានកម្រិតខ្ពស់មួយក្នុងការពិនិត្យឡើងវិញអំពីសំណើប្តឹងឧទ្ធរណ៍៖ តុលាការទាំងនោះមិនបានជ្រៀតជ្រែកជាមួយឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះនៃបណ្តឹងលើកទីដំបូងទេ តុលាការទាំងនោះរក្សានូវស្ថានភាពដោយឡែកមួយ ។ នៅពេលអង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការICTY បានពិនិត្យមើលក្នុងរឿងក្តី *Milosevic* ការ សម្រេចត្រូវតែ “*មិនសមហេតុផល ដើម្បីបង្ហាញថាអង្គជំនុំជម្រះសាលាដំបូងបរាជ័យក្នុងការអនុវត្ត ឆន្ទានុសិទ្ធិរបស់ខ្លួនបានត្រឹមត្រូវ* នៅមុនពេលការសម្រេចនោះត្រូវបានលុបចោល”។ អង្គជំនុំជម្រះឧទ្ធរណ៍នៅតុលាការពិសេសសំរាប់ប្រទេសសេរ៉ាលេអូន បានអនុម័តនូវបទដ្ឋានដូចគ្នាសំរាប់ការពិនិត្យសារឡើងវិញរបស់តុលាការអំពីការសម្រេចដោះលែងឱ្យនៅក្រៅឃុំដោយមានការធានា។ ក្នុងរឿងក្តី *Fofana* អង្គជំនុំជម្រះបាន

00154460

សម្រេចថា "*នៅពេលណាចៅក្រម ឬអង្គជំនុំជម្រះសាលាដំបូង បានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការផ្តល់ ឬបដិសេធចំពោះការដោះលែងឱ្យនៅក្រៅឃុំ អង្គជំនុំជម្រះឧទ្ធរណ៍នឹងមិនដាក់ជំនួសនូវឆន្ទានុសិទ្ធិផ្ទាល់របស់ខ្លួនទៅឱ្យចៅក្រម ឬអង្គជំនុំជម្រះសាលាដំបូងនោះឡើយ*"។ អង្គជំនុំជម្រះបានបន្ថែមទៀតថា ការសម្រេចបដិសេធចោលនូវការធានាឱ្យនៅក្រៅឃុំ ត្រូវលុបចោល ប្រសិនបើវាមានលក្ខណៈ "សមស្រប និងច្បាស់លាស់"។

៣៩. សេចក្តីសម្រេចរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលជាការគួរឲ្យសោកស្តាយព្រោះវាមានកំហុសឆ្គងនៃអង្គហេតុជាក់លាក់ (ដូចដែលនឹងលើកយកមកពិភាក្សាខាងក្រោម) ទំនងជាមិនបានបង្ហាញឲ្យឃើញថាវាពិតជាបានឈានទៅរកការឆ្លងឲ្យផុតពីកម្រិតខ្ពស់នៃភាពមិនសមហេតុផលទេ។ អង្គជំនុំជម្រះឧទ្ធរណ៍ទាំង ICTY និង ICTR និងតុលាការពិសេសសំរាប់ប្រទេស សេរ៉ាលេអូន បានបញ្ជាក់ច្បាស់ថា អង្គជំនុំជម្រះឧទ្ធរណ៍អាចពិនិត្យមើលជាថ្មីត្រឹមតែអង្គហេតុទាំង ឡាយដែលកំណត់ដោយអង្គជំនុំជម្រះសាលាដំបូងប៉ុណ្ណោះ នៅពេលដែល អ្នកជំនុំជម្រះសមហេតុ ផលមួយនៃអង្គហេតុមិនអាចធ្វើសេចក្តីសន្និដ្ឋានដូចគ្នា ឬប្រសិនបើសេចក្តីសម្រេចនោះមានកំហុសឆ្គងទាំងស្រុង។ ដូចបានកត់សំគាល់ដោយអង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការ ICTR ក្នុងរឿងក្តីរបស់ *Semanza*:

> "អង្គជំនុំជម្រះឧទ្ធរណ៍បញ្ជាក់អំពីការពិត ក្នុងពេលប្តឹងឧទ្ធរណ៍ ដែលភាគីមិនអាច លើកមកជជែកវែកញែកច្រំដែលៗ នូវការជំនុំជម្រះដែលមិនបានជោគជ័យ ដោយសង្ឃឹមថាអង្គជំនុំជម្រះ ឧទ្ធរណ៍ពិចារណាជាថ្មីឡើងវិញនោះឡើយ។
>
> នីតិវិធីប្តឹងឧទ្ធរណ៍ គឺមិនមែនជាការជំនុំជម្រះចាប់ពីដំបូងនោះឡើយ ហើយអង្គជំនុំជម្រះឧទ្ធរណ៍គឺមិនមែនជាអ្នកជំនុំជម្រះទីពីរនៃអង្គហេតុនោះដែរ។

៤០. ចំនុចនេះមិនអ្វីពីបណ្តឹងឧទ្ធរណ៍ដក្នុងដំណាក់កាលមុនការជំនុំជម្រះ ដែលបានដាក់ប្តឹងទៅអង្គជំនុះជម្រះដ៏មានកិត្តិយសមួយនេះឡើយ។ ការិយាល័យសហចៅក្រមស៊ើបអង្កេត បានគ្រោងយ៉ាងច្បាស់លាស់នូវកត្តាដែលត្រូវយកមកពិចារណាដើម្បីធ្វើសេចក្តីសន្និដ្ឋានក្នុង កថាខណ្ឌ២២ និង២៣។ បើទោះណាជាអង្គជំនុះជម្រះដ៏មានកិត្តិយសនេះមិនបានយល់ស្របជាមួយនឹងសេចក្តីសម្រេចរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត យ៉ាងណាក៏ដោយ ក៏ការមិនយល់ស្របបែបនេះមិនមែនជាមូលហេតុដើម្បីបដិសេធសេចក្តីសម្រេចនេះដែរ។ យុត្តិសាស្ត្រស្តីអំពីបញ្ហានេះដូចជាមាននិន្នាការទៅរកការសន្និដ្ឋានថា អង្គជំនុះជម្រះដ៏មានកិត្តិយសនេះមិនត្រូវពិចារណាការខ្វែងគំនិតជាថ្មី ឬប្រើឆន្ទានុសិទ្ធិ

ផ្ទាល់របស់ខ្លួនដើម្បីជំនួសឆន្ទានុសិទ្ធិរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតក្នុងការបញ្ជាឲ្យឃុំខ្លួនបណ្តោះអាសន្ននោះទេ។ បើសិនជាអង្គបុរេជំនុំជម្រះបដិសេធសេចក្តីសម្រេចរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត យើងជម្រុញឲ្យអង្គជំនុំជម្រះនេះពន្យល់អំពីភាពខុសគ្នារវាងបទដ្ឋាននៃត្រួតពិនិត្យឡើងវិញ និងបទដ្ឋាននៃសាលាក្តីក្អូនកាត់ និងសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិផ្សេងៗ ការអនុវត្តន៍ និងយុត្តិសាស្ត្រដែលជាប្រភពច្បាប់ដែលមានឥទ្ធិពលបញ្ចុះបញ្ចូលដើម្បីយកមកប្រើប្រាស់សម្រាប់អង្គជំនុះជម្រះដ៏មានកិត្តិយសនេះ។

៤១. ក្នុងករណីដែល អង្គជំនុះជម្រះដ៏មានកិត្តិយសនេះសម្រេចថាវាស្របតាមកម្រិតដែលតម្រូវឲ្យមានការពិនិត្យសេចក្តីសម្រេចរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតឡើងវិញបាន ពេលនេះខ្លួនត្រូវតែយកមកពិចារណានូវកត្តាសំខាន់ផ្សេងមួយទៀតផងដែរ ឧទាហរណ៍ ការិយាល័យសហចៅក្រមស៊ើបអង្កេត អាចពិនិត្យមើលឡើងវិញនូវដីកាបង្គាប់ឱ្យឃុំខ្លួន នៅក្នុងកាលបរិច្ឆេទនាពេលអនាគតដោយធ្វើតាមរយៈញត្តិរបស់ខ្លួនផ្ទាល់២៤។

៤២. អង្គជំនុះជម្រះដ៏មានកិត្តិយសនេះ ត្រូវកត់សំគាល់អំពីនីតិវិធីត្រួតពិនិត្យឡើងវិញតាមពេលកំនត់ដូចមានចែងក្នុងវិធានផ្ទៃក្នុង ដែលអាចខុសពីវិធានអំពីការឃុំខ្លួន និងការដោះលែងបណ្តោះអាសន្ននៅក្នុងសាលាក្តីព្រហ្មទណ្ឌអន្តរជាតិផ្សេងៗ២៥។ មិនដូចវិធាននៃសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រ៉ូវ៉ាន់ដា និងតុលាការពិសេសសម្រាប់សេរ៉ាលេអូន វិធាន៦៤និងវិធាន៦៥នៃវិធានផ្ទៃក្នុងចែងថា ដីកាបង្គាប់ឱ្យឃុំខ្លួនមុនការកាត់ទោសគឺគ្រាន់តែមានលក្ខណៈបណ្តោះអាសន្នប៉ុណ្ណោះ និងការិយាល័យសហចៅក្រមស៊ើបអង្កេតត្រូវបានប្រគល់ជូននូវឆន្ទានុសិទ្ធិបន្ថែមឲ្យពិនិត្យដីការបស់ខ្លួនឡើងវិញ និងអំពាវនាវឲ្យដោះលែង ភាគីប្តឹងឧទ្ធរណ៍ក្នុងពេលក្រោយមកទៀត។ ភាគីប្តឹងឧទ្ធរណ៍ក៏អាចដាក់ពាក្យបណ្តឹងសុំនៅក្រៅឃុំ ទៅកាន់ការិយាល័យសហចៅក្រមស៊ើបអង្កេត អំឡុងពេលដែលគាត់កំពុងស្ថិតក្នុងការឃុំខ្លួនជាបណ្តោះអាសន្ន ដែលគាត់អាចឧទ្ធរណ៍សេចក្តីសម្រេចរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ឬដាក់ពាក្យសុំបន្ថែមក្នុងចន្លោះពេលបីខែដែលស្វែងរកការពិចារណាឡើងវិញនូវដីការបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត បើសិនជាគាត់អាចបង្ហាញថាមានការប្រែប្រួលនៅក្នុងកាលៈទេសៈរបស់គាត់។

00154462

៤៣. ការពិតដែល អ. វ. ត. ក មាននីតិវិធីត្រួតពិនិត្យនិងពិនិត្យឡើងវិញម្តងម្កាលដើម្បីធានាថា ការឃុំខ្លួនបន្តគឺជាការចាំបាច់ ត្រូវតែយកមកពិចារណានូវទឡ្ហីករណ៍របស់ភាគីប្តឹងឧទ្ធរណ៍ដើម្បីឲ្យដោះលែងគាត់ភ្លាមៗ២៦។ ជាពិសេស គេត្រូវតែចងចាំថា ដីកាបង្គាប់ឱ្យឃុំខ្លួនមិនមែនដើម្បីដកសិទ្ធិរបស់ ភាគីប្តឹងឧទ្ធរណ៍មិនឲ្យគាត់ស្វែងរកមធ្យោបាយដោះស្រាយបន្ថែមនៅក្នុងដំណាក់កាលនៃការឃុំខ្លួនគាត់ក្រោយៗមកទៀតនោះឡើយ។ បើសិនជាការឃុំខ្លួនគាត់ជាបណ្តោះអាសន្នបញ្ជាក់ច្បាស់ថាមិនចាំបាច់អ្វីនោះទេ ក្នុងករណីបែបនេះ ភាគីប្តឹងឧទ្ធរណ៍ត្រូវតែមានសិទ្ធិជាប្រាកដក្នុងការស្វែងរកការដោះលែងខ្លួនគាត់។

***ខ) គួរឱ្យសោកស្តាយ ការកំហុសឆ្គងនៃអង្គហេតុក្នុងការសំអាងហេតុផលរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតបន្ទាប់ពីដីកាបង្គាប់ឱ្យឃុំខ្លួន មិនមែនជាកំហុសដែលអាចប្តឹងឧទ្ធរណ៍បានឡើយ។***

៤៤. បើទោះណាជាពិចារណាអំពីមូលហេតុច្បាប់ចំពោះសេចក្តីសម្រេចរបស់ខ្លួននៅក្នុងដីកាបង្គាប់ឱ្យឃុំខ្លួនដែលមានកម្រាស់១០ទំព័រក៏ដោយ ក៏យើងកត់សំគាល់ថា ការិយាល័យសហចៅក្រមស៊ើបអង្កេតបានផ្តល់ពេលវេលាមានកំរិតស្តីពីការពិភាក្សាមូលដ្ឋាននៃអង្គហេតុដែលគាំទ្រដល់សេចក្តីសម្រេចចិត្ត នោះ ពោលគឺគេបែងចែកឲ្យមិនលើសពី២កថាខណ្ឌចុងក្រោយទេសម្រាប់គោលបំណងនេះ។

៤៥. យើងយល់ថាសេចក្តីសម្រេចជាឆន្ទានុសិទ្ធិដូចជាដីកាបង្គាប់ឱ្យឃុំខ្លួនមិនត្រូវអមដោយបញ្ជីមូលហេតុដ៏ទូលំទូលាយមួយទេ លើកលែងតែគ្រោះថ្នាក់ពិតប្រាកដត្រូវបានបង្ហាញផងដែរ២៧។ ក៏ប៉ុន្តែនៅមានការលើកឡើងផងដែរថាការិយាល័យសហចៅក្រមស៊ើបអង្កេតបានបរិយាយតិចតួចអំពីហេតុការណ៍នៅក្រោយគ្រោះថ្នាក់ដ៏ពិតប្រាកដនេះ។ ឧទាហរណ៍ ការិយាល័យសហចៅក្រមស៊ើបអង្កេតមិនបានបង្ហាញភស្តុតាងដើម្បីគាំទ្រការអះអាងរបស់ខ្លួនដែលថា "នៅក្នុងបរិបទផុយស្រួយនៃសង្គមកម្ពុជាបច្ចុប្បន្ន" គឺបទឧក្រិដ្ឋនៃភាគីប្តឹងឧទ្ធរណ៍មានភាពធ្ងន់ធ្ងរខ្លាំងណាស់ ដែលការដោះលែងរូបគាត់អាចនាំឲ្យ "មានការតវ៉ាដោយការឈឺចាប់ក្នុងចិត្ត ដែលប្រការនេះអាចបណ្តាលឲ្យមានអំពើហិង្សា" ក្នុងចំណោមប្រជាពលរដ្ឋដែលអាច "ធ្វើឲ្យអន្តរាយដល់សុវត្ថិភាព" ផ្ទាល់របស់ភាគីប្តឹងឧទ្ធរណ៍២៨ នោះក៏ទេដែរ។

៤៦. យុត្តិសាស្ត្រនេះសន្និដ្ឋានថា កំហុសឆ្គងនៃអង្គហេតុទាំងនេះគឺជាកំហុសឆ្គងដែលមិនអាចទទួលយកបានឡើយ (ដូចបានបញ្ជាក់ជូនខាងលើ)។ ម្យ៉ាងវិញទៀត សេចក្តីថ្លែងការណ៍របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលបកស្រាយខាងលើក៏ដូចជាសេចក្តីថ្លែងការណ៍ផ្សេងៗដែលមាននៅក្នុងកថាខណ្ឌ២២ និងកថាខណ្ឌ២៣នៃដីកាបង្គាប់ឱ្យឃុំខ្លួនមិនមែនគ្មានហេតុផលរឹងមាំ ឬ ខ្វះភាពពិចារណាយ៉ាងហ្មត់ចត់នោះដែរ។ ការពិត បើទោះណាជាមិនបានបញ្ជាក់ជាពិសេសនៅក្នុងដីកាបង្គាប់ឱ្យឃុំខ្លួនក៏ដោយ ក៏សេចក្តីថ្លែងការណ៍ទាំងនេះមិនមែនគ្មានការគាំទ្រទាំងស្រុងពីទស្សនៈនៃដ៏លើសលុបនៃការស្រាវជ្រាវ និងការសរសេររបស់អង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ និងបញ្ញាជនដ៏ឧត្តម ចំពោះចំណាប់អារម្មណ៍របស់សាធារណៈជនក្នុងពេលបច្ចុប្បន្នស្តីពីការឃុំខ្លួនបណ្តោះអាសន្ននៃភាគីប្តឹងឧទ្ធរណ៍ និងការជំនុំជម្រះក្តីនៅចំពោះមុខ អ.វ.ត.ក នោះដែរ។

៤៧. នៅក្នុងកាលៈទេសៈបែបនេះ យើងសូមជម្រុញឱ្យ អង្គជំនុំជម្រះដ៏មានកិត្តិយសនេះផ្តល់ការណែនាំយ៉ាងច្បាស់ដល់នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនទៅការិយាល័យសហចៅក្រមស៊ើបអង្កេតអំពីរបៀបដែលខ្លួនអាចរៀបចំមូលដ្ឋាននៃអង្គហេតុសម្រាប់ការឃុំខ្លួននៅក្នុងគ្រប់ករណី ដោយអនុលោមទៅតាមវិធាន ៦៣(២)(ក) និង(៣) នៃវិធានផ្ទៃក្នុង។

*គ) ភាគីប្តឹងឧទ្ធរណ៍មានបន្ទុកក្នុងការបង្ហាញឱ្យឃើញអំពីហេតុផលដែលថាដីកាដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ ពិតជាគួរត្រូវយកមកជំនួសដីកាបង្គាប់ឱ្យឃុំខ្លួន ដែលចេញឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត។*

៤៨. បន្ទុកភស្តុតាងគឺត្រូវធ្លាក់ទៅលើភាគីប្តឹងឧទ្ធរណ៍ធ្វើឱ្យអង្គបុរេជំនុំជម្រះអស់ចិត្តចំពោះការដែលថាដីកាដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ ពិតជាគួរត្រូវយកមកជំនួសដីកាបង្គាប់ឱ្យឃុំខ្លួន របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត២៩។ ភាគីប្តឹងឧទ្ធរណ៍ត្រូវលើកមូលហេតុជាច្រើនដើម្បីបង្ហាញថាគាត់នឹងមិនរត់គេចពីយុត្តិធម៌ទេ៣០ បើសិនជាគេដោះលែងគាត់។ គាត់បញ្ជាក់នៅក្នុងសារណាបណ្តឹងឧទ្ធរណ៍ផងដែរថា សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី៣១ បាន

យល់ព្រមឲ្យជនជាប់ចោទនៃបទឧក្រិដ្ឋសាហាវយង់ឃ្នង ដូចគ្នានឹងបទឧក្រិដ្ឋដែលភាគីប្តឹងឧទ្ធរណ៍កំពុងត្រូវបានចោទប្រកាន់ដែរនោះ បានដាក់ពាក្យប្តឹងដូចអញ្ចឹងដែរ។

៤៩. ការពិនិត្យឡើងវិញលើករណីរបស់សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីស្តីដែលភាគីប្តឹងឧទ្ធរណ៍យកធ្វើជាសំអាងនោះ បង្ហាញថាលក្ខខណ្ឌទាំងអស់ ឬភាគច្រើន ត្រូវបង្ហាញនៅក្នុងបណ្តឹងដែលស្វះស្វែងរកការបញ្ចុះបញ្ចូលសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិថាអ្នកដាក់ពាក្យប្តឹងត្រូវបានផ្តល់សិទ្ធិដោះលែងបណ្តោះអាសន្នឬឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ ដូចខាងក្រោម:

(i) សេចក្តីថ្លែងការណ៍ជាសាធារណៈដោយជនជាប់ចោទថា គាត់នឹងមិនតតាំងជាមួយនឹងសាលាក្តីនេះទេ ឬថាគាត់គោរពតាមដំណើរការរបស់តុលាការ។

(ii) សេចក្តីយោងអំពីអត្តចរិតពាក់ព័ន្ធនឹងសុចរិតភាពផ្ទាល់របស់ជនជាប់ចោទ ដែលរួមមានសេចក្តីប្រកាសពីរដ្ឋាភិបាលដែលជាប់ទាក់ទង ឬពីការិយាល័យអង្គការសហប្រជាជាតិចំពោះបញ្ហានេះ។

(iii) ការធានាអះអាងជាលាយលក្ខណ៍អក្សរដោយជនជាប់ចោទថាគាត់នឹងប្រតិបត្តិតាមលក្ខខណ្ឌនៃការដោះលែងគាត់ជាបណ្តោះអាសន្ន និង

(iv)ការធានាអះអាងជាលាយលក្ខណ៍អក្សរពីរដ្ឋាភិបាលជាប់ពាក់ព័ន្ធថា ពួកគេមានមធ្យោបាយនិងលទ្ធភាពចាប់ជនជាប់ចោទ បើសិនជាគាត់ព្យាយាមរត់គេច៣២។

៥០. ភាគីប្តឹងឧទ្ធរណ៍ថ្លែងជាសាធារណៈថា គាត់នឹងមិនរឹងទទឹងចំពោះ អ.វ.ត.ក ទេ។ សារណាបណ្តឹងឧទ្ធរណ៍មានបញ្ចូលសេចក្តីលំអិតអំពីកិច្ចសហការរបស់ភាគីប្តឹងឧទ្ធរណ៍ជាមួយនឹងសាលាក្តីដែរ។ មេធាវីរបស់ភាគីប្តឹងឧទ្ធរណ៍ក៏បានយល់ព្រមធានាដោយផ្ទាល់ខ្លួនថា ភាគីប្តឹងឧទ្ធរណ៍នឹងមានវត្តមាននៅក្នុងតុលាការ។

៥១. កត្តាទាំងនេះពិតជាគុណប្រយោជន៍របស់ភាគីប្តឹងឧទ្ធរណ៍។

00154465

៥២. ទោះជាយ៉ាងនេះក្តី នៅមានឧបសគ្គពីរ ក្នុងករណីដែលគេដោះលែងភាគីប្តឹងឧទ្ធរណ៍ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ ឬដោះលែងបណ្តោះអាសន្ន។

៥៣. ដំបូង បើទោះណាជា ភាគីប្តឹងឧទ្ធរណ៍ (ឬក៏មេធាវីរបស់គាត់) បានសំដែងកាយវិកាមានបំណងល្អនិងត្រៀមរៀបចំធានានាអំពីការបង្ហាញខ្លួនក្នុងតុលាការក៏ដោយ ក៏ "ការធានានេះគឺអាចយកជាការបាន ទាល់តែអ្នកដាក់ពាក្យប្តឹងអាចរៀបចំបង្កើតការធានានេះបាន ដោយយ៉ាងហោចណាស់ក៏ត្រូវធ្វើឲ្យតុលាការពេញចិត្តទទួលយកបានផងដែរ"[៣៣]។

៥៤. ពុំមានសិទ្ធិអ្វីក្នុងការដោះលែងជនជាប់ចោទឲ្យស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការឡើយ ក្នុងករណីដែលជនជាប់ចោទមានសិទ្ធិទទួលបានការដោះលែងឲ្យមានសេរីភាពហើយនោះ លើកលែងតែអាជ្ញាធរតុលាការអាចបញ្ជាក់ឲ្យឃើញនូវការចោទប្រកាន់ណាមួយជាពិសេសប្រឆាំងលើរូបគាត់។ បើមិនដូច្នេះទេ វាគឺជាសិទ្ធិមួយក្នុងការដាក់ពាក្យប្តឹងសុំនៅក្រៅឃុំក្រោមការត្រួតពិនិត្យរបស់តុលាការបាន ចំពោះមុខតុលាការមួយដែលបើកចំហឲ្យមានការលើកសំអាងថា ការឃុំខ្លួនបណ្តោះអាសន្នលើជនជាប់ចោទគឺមិនមែនមានន័យថាវាពិតជាអាចធានាបាននូវប្រសិទ្ធិភាពនៃការជំនុំជម្រះក្តីឬហេតុផលសាធារណៈណាផ្សេងមួយទេនោះ [៣៤]។

៥៥. ដូចចៅក្រម David Hunt បានចាប់អារម្មណ៍ក្នុង Sainovic ថា:

> "កាលណាមានការពោលអះអាងលើបញ្ហាកាន់តែធ្ងន់ ឬកាលណាព្យសនកម្មដែលបានមកពីការរកឃើញពិសេសណាមួយមានភាពកាន់តែធ្ងន់ នោះមានន័យថាវាកាន់តែមានការលំបាកកាន់តែខ្លាំងក្នុងការផ្គាប់ចិត្តសាលាក្តីដែលពាក់ព័ន្ធ ព្រោះអ្វីដែលត្រូវបានពោលអះអាងរួចហើយវាប្រហែលជាពិត ជាងមិនពិត។ នោះគឺសុភនិច្ឆ័យសាមញ្ញទូទៅប៉ុណ្ណោះ៣៥។

៥៦. គេត្រូវតែធ្វើឲ្យអង្គជំនុំជម្រះដ៏មានកិត្តិយសនេះជឿថា បើសិនជាមានការដោះលែងឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការក្នុងរឿងនោះ តើភាគីប្តឹងឧទ្ធរណ៍នឹងមកបង្ហាញខ្លួនក្នុងតុលាការដែរឬយ៉ាងណា។ នៅក្នុងការធ្វើសេចក្តីសម្រេចបែបនេះ អង្គជំនុំជម្រះត្រូវដឹងអំពីទម្ងន់ និងភាព

00154466

ជាក់ស្តែងនៃបទឧក្រិដ្ឋ ដែលភាគីប្តឹងឧទ្ធរណ៍ត្រូវបានចោទប្រកាន់ពាក់ព័ន្ធនឹងមន្ទីរស២១ ក៏ដូចជាផលត្រលប់ដែលនឹងអាចមានទៅលើសាធារណជនកម្ពុជា និងសេចក្តីទុកចិត្តរបស់ពួកគេលើនីតិរដ្ឋក្នុងទេសកម្ពុជា ប្រសិនបើមានការដោះលែងភាគីប្តឹងឧទ្ធរណ៍ជាបណ្តោះអាសន្ននេះ ។ អង្គជំនុះជម្រះដ៏មានកិត្តិយសនេះក៏ត្រូវតែពិចារណាលទ្ធភាពដែលថាភាគីប្តឹងឧទ្ធរណ៍អាចមានបំណងរត់គេចពីចំណាត់ការផ្លូវច្បាប់ ដើម្បីគេចវេសពីការកាត់ទោសដាក់ពន្ធនាគារអស់មួយជីវិត។ បើទោះណាជាភាគីប្តឹងឧទ្ធរណ៍អះអាងនៅក្នុងសារណាបណ្តឹងឧទ្ធរណ៍របស់គាត់ថា គាត់គ្មានមធ្យោបាយប្រាក់កាសដើម្បីធ្វើដូច្នេះបានយ៉ាងណាក៏ដោយ ក៏អង្គជំនុំជម្រះគួរតែផ្អែកទៅលើភស្តុតាងបន្ថែមនៃភាពក្រីក្ររបស់គាត់ គឺភស្តុតាងដែលបានផ្តល់រួចទៅហើយ ដើម្បីគាត់អាចសុំមេធាវីការពារក្តីឲ្យគាត់នោះ ក៏ប៉ុន្តែចំនុចនោះមិនមានរួមបញ្ចូលក្នុងផ្នែកមួយនៃសារណាបណ្តឹងឧទ្ធរណ៍ទេ។

៥៧. ទីពីរ ផ្នែក(iv)ក្នុងកថាខណ្ឌ៤៩ខាងលើ ខុសពីពាក្យបណ្តឹងដោះលែងឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការនៃភាគីប្តឹងឧទ្ធរណ៍។ រឿងនេះហាក់ដូចជាការបដិសេធគ្រប់គ្រាន់មួយ។ បើទោះណាជា ភាពពិតនៃប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជាខុសពីភាពពិតដែលទាក់ទងទៅនឹងសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីយ៉ាងណាក្តី ក៏យ៉ាងហោចណាស់គេរំពឹងថាការធានារ៉ាប់រងមួយចំនួនពីក្រសួងពាក់ព័ន្ធនៃរាជរដ្ឋាភិបាលកម្ពុជា ដែលអះអាងថាពួកគេមានលទ្ធភាពធានាថាភាគីប្តឹងឧទ្ធរណ៍នឹងមិនអាចរត់គេចចេញពីប្រទេសដែលគាត់ត្រូវបានដោះលែងនោះទេ។ ការធានាអះអាងបែបនេះទើបនឹងត្រូវបានធ្វើឡើងនាពេលបច្ចុប្បន្ននេះឯង។

### *ឃ) ការជំនុំជម្រះក្តីភាគីប្តឹងឧទ្ធរណ៍ខិតជិតមកដល់ណាស់ហើយ*

៥៨. លើសពីនេះទៀត នៅពេលបញ្ហាឱ្យដោះលែងបណ្តោះអាសន្ន សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី យកចិត្តទុកដាក់អំពីរយៈពេលដែលជនជាប់ចោទត្រូវរង់ចាំការកាត់ទោស។ ឧទាហរណ៍ ករណី Ademi ដែលភាគីប្តឹងឧទ្ធរណ៍សំអាងលើ អង្គជំនុំជម្រះសាលាដំបូងពិចារណាអំពីហេតុការណ៍ដែលវា "មើលទៅទំនងជាការកាត់ទោសជនជាប់ចោទនឹងចាប់ផ្តើមក្នុងពេលឆាប់ៗ៣៦"។ រយៈពេលដែលភាគីប្តឹងឧទ្ធរណ៍ទំនងជានឹងត្រូវចំណាយនៅក្នុងការឃុំខ្លួនបន្តទៀតគួរត្រូវគេយកមកពិចារណា នៅពេលណា សម្រេចថាតើត្រូវដោះលែង ឬមិនដោះលែងគាត់ជាបណ្តោះអាសន្ន

00154467

ព្រមទាំងអ្វីៗទាំងឡាយដែលចាំបាច់ត្រូវមានដើម្បីធានាថាភាគីប្ដឹងឧទ្ធរណ៍នៅតែជាស្ថិតក្នុងក្របខ័ណ្ឌនៃយុត្តិធម៌បាន។ ការឃុំខ្លួនបន្ថែម៦ខែទៀត ដែលអាស្រ័យលើការពិនិត្យឡើងវិញរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ធ្វើឱ្យរយៈពេលនៃការឃុំខ្លួនភាគីប្ដឹងឧទ្ធរណ៍ខុសប្លែកពីរយៈពេលនៃយុត្តិសាស្ត្រដែលគាត់យកមកធ្វើជាទីសំអាង។

**សេចក្ដីសន្និដ្ឋាន**

៥៩. យើងសង្ឃឹមថា យោបល់របស់យើងនឹងជួយអង្គជំនុះជម្រះដ៏មានកិត្តិយសនេះ ឈានដល់ការសេចក្ដីសម្រេចសមហេតុផលថាតើការឃុំខ្លួនមុនការកាត់ទោសភាគីប្ដឹងឧទ្ធរណ៍យូរជាង៨ឆ្នាំជាការរំលោភសិទ្ធិដែរឬយ៉ាងណា។ បើសិនជា អង្គជំនុះជម្រះដ៏មានកិត្តិយសនេះយល់ស្របជាមួយយើងថាវាជាការរំលោភសិទ្ធិមែន យើងសូមស្នើសុំឱ្យអង្គជំនុះជម្រះដ៏មានកិត្តិយសនេះប្រកាសរឿងនេះជាសាធារណៈ និងគិតមើលថាតើវាពិតជាមធ្យោបាយដោះស្រាយសមស្របមួយដែរឬទេ ត្បិតអីភាគីប្ដឹងឧទ្ធរណ៍កំពុងស្ថិតក្នុងដំណាក់កាលកាត់ទោស។ លើសពីនេះទៀត យើងបានបង្ហាញការស្ទាបស្ទង់យុត្តិសាស្ត្រពាក់ព័ន្ធ និងការអនុវត្តន៍របស់សាលាក្ដីឧក្រិដ្ឋកម្មកូនកាត់និងសាលាក្ដីឧក្រិដ្ឋកម្មអន្តរជាតិផ្សេងៗដើម្បីជួយអង្គជំនុះជម្រះដ៏មានកិត្តិយសនេះក្នុងការធ្វើសេចក្ដីសម្រេច បើសិនជាការិយាល័យសហចៅក្រមស៊ើបអង្កេតត្រូវបានផ្ដល់សិទ្ធិឱ្យអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការបញ្ជាឱ្យឃុំខ្លួនភាគីប្ដឹងឧទ្ធរណ៍បណ្ដោះអាសន្ន និងថាតើការធ្វើដូច្នេះរបស់ការិយាល័យនេះគួរត្រូវពិនិត្យឡើងវិញដែរឬយ៉ាងណា។ យើងសូមស្នើ ថាយ៉ាងណាៗ ដាច់ខាតត្រូវតែរក្សាឱ្យបាននូវតុល្យភាពរវាងផលប្រយោជន៍សាធារណៈ និងម្យ៉ាងទៀតត្រូវធានាអះអាងអំពីការគោរពសិទ្ធិសេរីភាពភាគីប្ដឹងឧទ្ធរណ៍ផង។ ជាទីបញ្ចប់ អង្គជំនុំបុរេជំនុំជម្រះអាចយកវាជាជំនួយក្នុងការសម្រេចថាតើសេចក្ដីសម្រេចជាឆន្ទានុសិទ្ធិរបស់វិយាល័យសហចៅក្រមស៊ើបអង្កេតដែលលំអៀងទៅខាងចំនុចខាងដើម ពិតជាគ្មានហេតុផលជាក់ស្ដែងក្នុងកាលៈទេសៈនេះ ឬយ៉ាងណា។

គំនិតផ្ដួចផ្ដើមយុត្តិធម៌អន្តរជាតិអាស៊ី
មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម

ថ្ងៃទី៣ ខែតុលា ឆ្នាំ២០០៧